# ជំពូកទី៥ : លទ្ធផលនៃការស្រាវជ្រាវ

## ក- ធនធានរូបសាស្ត្រ

**៦៣.** ដីនេះស្ថិតនៅតំបន់ខ្ពង់រាបក្នុងរយៈកំពស់១០១-២៥០ម ធៀបនឹងកំពស់ទឹកសមុទ្រ ទទួលរបបទឹកភ្លៀងជាមធ្យម ១៥៦៩-១៥៩២មម សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ២៦.៥៤ដឺក្រេសែលស៊ីស រដូវប្រាំងមានរយៈពេលច្រើនជាង ៤ខែ (DANIDA, 2003)។ តាមការសិក្សាទៅលើកំពស់ទឹកភ្លៀងដែលបានមកពីស្ថានីយ៍ ព្រះវិហារ នៅក្នុងរយៈពេល ៨ឆ្នាំចុងក្រោយនេះ(២០០២-២០០៩) បានអោយដឹងថា មធ្យមភាគ កំពស់ទឹកភ្លៀងប្រចាំឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី ១៣៤៥.៥-២០៦៩.៥ ម.ម (ឧបសម្ព័ន្ធទី ៥-៣)។

**៦៤.** ដីជាតិដីអាចកំណត់ដោយសិលាមេដែលមានស្ថិតនៅស្រទាប់ក្រោម។ លក្ខណៈគីមីរបស់ដីតែងតែបញ្ជាក់អំពីកំរិត និងលំនាំនៃការបំបែកធាតុរបស់សិលាមេក្នុងយុគសម័យភូគព្ភសាស្ត្រ និងលក្ខណៈរបស់ថ្មដែលជាសិលាមេ។ ដំណើរប្រព្រឹត្តទៅនៃបាតុភូតភូគព្ភសាស្ត្រនេះបានទទួលរងនូវឥទ្ធិពលអាកាសធាតុ ពេលវេលា ទំនាក់ទំនងនិងដំណើរប្រព្រឹត្តទៅតាមលក្ខណៈជីវសាស្ត្រធម្មជាតិ លក្ខណៈជីវសាស្ត្រដែលបង្កឡើងដោយមនុស្ស សត្ត និងបាក់តេរី ។ កត្តាទាំងអស់នេះអាចបញ្ជាក់ដោយផ្ទាល់ និងដោយប្រយោលអំពីដីដែលមានលក្ខណៈជាអាស៊ីត ពណ៌ រចនាសម្ព័ន្ធ ជីជាតិ លទ្ធភាពផលិតកម្ម និងភាពជ្រាបទឹក។ យោងតាមផែនទីភូគព្ភសាស្ត្រ (ឧបសម្ព័ន្ធ ៥-១:ផែនទី១) បង្ហាញថាដី សម្បទានមានសិលាមេ៤ប្រភេទ:

**តារាង ៥-១: បង្ហាញស្ថានភាពសិលាមេ**

| ល.រ | ប្រភេទសិលាមេ | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|---|
| ១ | Granodiorite | ២ | ២ |
| ២ | No Classified rock | ៤២ | ៤២ |
| ៣ | Pediments | ២៨ | ២៨ |
| ៤ | Peneplain Laterite Deposits | ២៨ | ២៨ |
| | **សរុប** | **១០០** | **១០០** |

**៦៥.** យោងតាមលក្ខណៈដី និងទំនាបលេខា និងផែនទីចំណាត់ថ្នាក់ប្រភេទដី (ឧបសម្ព័ន្ធ៥-១:ផែនទី២) នៅតំបន់ស្រាវជ្រាវ និងរុករករ៉ែនេះគ្របដណ្ដប់ទៅដោយដី ០២ប្រភេទគឺ:

តារាង ៥-២: បង្ហាញចំណាត់ថ្នាក់ប្រភេទដី

| ល.រ | ចំណាត់ថ្នាក់ប្រភេទដី | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|---|
| ១ | Grey hydromorphics | ៤៩ | ៤៩ |
| ២ | Plinthite podzols | ៥១ | ៥១ |
| **សរុប** | | **១០០** | **១០០** |

**៦៦.** យោងតាមចំណាត់ប្រភេទគុណភាពរបស់ដីនៅក្នុងតំបន់សម្បទានទាំងមូលមាន ០២ប្រភេទគឺ (១)ដីមានជីជាតិខ្ពស់ (High productivity soil) មានទំហំ ៤៦ហិកតា ឬស្មើនឹង ៤៦ភាគរយ លាតសន្ធឹងនៅទិសខាងលិច និង(២)ដីមានជីជាតិទាប (Low productivity soil) មានទំហំ ៥៤ហិកតា ឬស្មើនឹង ៥៤ ភាគរយ លាតសន្ធឹងនៅទិសខាងកើតតំបន់សម្បទាន (ឧបសម្ព័ន្ធ៥-១ : ផែនទី៣ ផែនទីចំណាត់ថ្នាក់ជីជាតិដី) ។ ដោយឡែកការពិនិត្យជាក់ស្តែងនៅលើទីវាលបង្ហាញថា តំបន់សម្បទាននេះដីភាគច្រើនជាដីដែលមានផលិតភាពខ្ពស់ ។ បញ្ហានេះអាចធ្វើការបកស្រាយបាន អំពីកំរិតលំអៀងនៅលើផែនទី ព្រោះថាផែនទីចំណាត់ថ្នាក់កំរិតផលិតភាពរបស់ដី ជាផែនទីខ្នាត ១ :១.000.000 ដូច្នេះ កំរិតលំអៀងមួយមីលីម៉ែត្រ នៅលើផែនទីគឺស្មើ ១០គម នៅលើទីវាល ។

តារាង ៥-៣: បង្ហាញចំណាត់ថ្នាក់ប្រភេទជីជាតិដី

| ល.រ | ចំណាត់ថ្នាក់ប្រភេទជីជាតិដី | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|---|
| ១ | High productivity soil | ៤៦ | ៤៦ |
| ២ | Low productivity soil | ៥៤ | ៥៤ |
| **សរុប** | | **១០០** | **១០០** |

**៦៧.** តាមរយៈការសិក្សាទៅលើលក្ខណៈរបស់ឋានលេខានិងចំណាត់ថ្នាក់ទីជំរាល (ឧបសម្ព័ន្ធ៥-១:ផែនទី៤) បង្ហាញអោយឃើញថា សណ្ឋានដីមានសភាពប្រែប្រួលជាមួយនឹងចំណាត់ថ្នាក់ទីជំរាលបីប្រភេទគឺ:

- ចំណាត់ថ្នាក់ធំជាង ៥ដឺក្រេ: ដីសម្បទានតំបន់នេះមានដីជំរាលចំណាត់ថ្នាក់ធំជាង ៥ដឺក្រេ មានចំនួន ៤ ហិកតា ឬស្មើនឹង ៤ភាគរយនៃផ្ទៃដីសរុប ដីតំបន់នេះមានលក្ខណៈចោតបន្តិចម្តងៗ ហើយសណ្ឋានដីមានលក្ខណៈច្រោះ។ សណ្ឋានដីប្រភេទនេះជានិច្ចជាកាលតែងជួបប្រទះនៅតាមតំបន់ខ្ពង់រាប។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយហើយធន់នឹងការហូរច្រោះជាងចំណាត់ថ្នាក់ទី១ខាងលើ។ ការប្រើប្រាស់ដីតំបន់នេះអាចមានលក្ខណៈជាការដាំឈើបែបផែនពាណិជ្ជកម្ម វាលស្មៅ និងការដាំរួមរវាងឈើ និងដំណាំកសិកម្ម ប្រសិនបើអនុវត្តវិធានការណ៍អភិរក្សបានត្រឹមត្រូវ។

- ចំណាត់ថ្នាក់ ២-៥ដឺក្រេ: ដីសម្បទានតំបន់នេះមានដីជំរាលចំណាត់ថ្នាក់២-៥ដឺក្រេ ចំនួន២២ហិកតា ឬស្មើនឹង២២ភាគរយនៃផ្ទៃដីសរុប។ ដីតំបន់នេះមានលក្ខណៈស្ទើររាបស្មើ មិនមានតម្រូវការនៃការអភិរក្សទឹក និងដីទេ។ តាមទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជម្រាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ។ ដីតំបន់នេះអាចប្រើប្រាស់សម្រាប់កសិកម្ម និងព្រៃឈើ។

- ចំណាត់ថ្នាក់ ០-២ដឺក្រេ: ដីសម្បទានតំបន់នេះមានដីជំរាលចំណាត់ថ្នាក់០-២ដឺក្រេ ចំនួន ៧៤ហិកតា ឬស្មើនឹង ៧៤ភាគរយនៃផ្ទៃដីសរុប ជាដីរាបស្មើ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ។ ដីតំបន់នេះអាចប្រើប្រាស់សំរាប់ដំណាំស្រូវ ដំណាំកសិកម្ម និងព្រៃឈើ ។

**៦៨.** យោងតាមផែនទីរយៈកំពស់ដី បង្ហាញថារយៈកំពស់មានការប្រែប្រួល (១) ០-២០ (២)២០-៤០ (៣)៤០-៦០ (៤)៦០-៨០ (៥)៨០-១០០ និង(៦)១០០-១២០ ដូច្នេះយើងឃើញថា វាស្ថិតនៅចន្លោះពី ០-១២០ ម៉ែត្រ ប្រៀបធៀបនឹងនីវូទឹកសមុទ្រ (ឧបសម្ព័ន្ធ៥-១ : ផែនទី៥ ផែនទីរយៈកំពស់ដី )។

**៦៩.** តាមការសង្កេតដោយរហ័សរបស់ក្រុមស្រាវជ្រាវបានបង្ហាញថា ជាទូទៅប្រភេទដីនៅតំបន់រុករករ៉ែរបស់ក្រុមហ៊ុន Delcom (Kampuchea) PTE. LTD. ជាប្រភេទដីប្រផេះក្រម៉ៅ និងល្បាយខ្សាច់លាយគ្រួសនៅតំបន់ជិតមាត់ទឹក និងបាតអូរជាប្រភេទដីមានជីជាតិបង្គួរ ដោយសារដីនេះព័ទ្ធជុំវិញដោយតំបន់ខ្ពង់រាបមានល្បាប់ហូរ នៅរាល់រដូវវស្សាជីតដ្ឋប្រផេះរបាយខ្សាច់មានថ្ម១ចុងដោយកន្លែង ជាពិសេសតាមដងអូរ ជីតដ្ឋលាយគ្រួស ដោយកន្លែងដែលជាប្រភេទដីមានជីជាតិមធ្យមសំរាប់ដំណាំកសិឧស្សាហកម្ម។

**៧០.** ដីសំរាប់ដំណាំកសិកម្មដែលក្រុមស្រាវជ្រាវបានជួបប្រទះមាននៅក្បែរអូរ ដែលជាតំបន់ព្រៃល្បោះ ចំណែកដីនៅតាមព្រៃពាក់កណ្តាលស្រោង ជាដីល្បាយខ្សាច់ពណ៌ប្រផេះកន្លែងខ្លះ មានពណ៌ក្រម៉ៅតែមានថ្មច្រើន។ រចនាសម្ព័ន្ធថ្នាក់ក្រោមជាប្រភេទស្មៅ ស្មៅព្រិច និងកូនឈើតូចៗ ប៉ុន្តែ នៅពេលចុះពិនិត្យអង្កេតឃើញថា ស្មៅស្រទាប់ក្រោមបានដុះលូតលាស់ខ្ជីល្អដោយសារដូវវស្សាមានភ្លៀងធ្លាក់ជោកជាំ។

**៧១.** នៅតំបន់ដីសម្បទាននេះមិនសំបូរប្រភពទឹកស្រទាប់លើច្រើនទេ ដោយសារប្រភពទឹកស្រទាប់លើទាំងនេះជាកូនអូរតូចៗ ដែលគ្មានទឹកដក់ ឬហូរឡើយនៅរដូវប្រាំង លើកលែងតែប្រព័ន្ធអូរសំខាន់ ០១គឺ អូរភ្នៅ ដែលហូរនៅទិសខាងលិចក្បែរតំបន់សម្បទានរ៉ែ ប៉ុន្តែរដូវប្រាំងអូរនេះបានរីងស្ងួតដោយកន្លែង។ នៅក្នុងដីសម្បទាននេះមានអូរខ្វាន់ធំមួយតែពុំមានទឹកទេ ក្រៅពីអូរនេះនៅមានដៃអូរជាច្រើនទៀតដែលហូរចាក់ពីទិសខាងកើតចូលអូរភ្នៅ ដែលភាគច្រើនស្ថិតនៅខាងក្រៅតំបន់ដីសម្បទានហើយហូរបន្តចូលទៅក្នុងស្ទឹងសែន។ ដោយហេតុថាក្រុមហ៊ុន Delcom (Kampuchea) PTE. LTD. គ្រោងធ្វើអាជីវកម្មរ៉ែមាសជាលក្ខណៈឧស្សាហកម្ម ទើបទៅថ្ងៃក្រោយប្រជាជននៅក្នុងតំបន់នេះមានការព្រួយបារម្ភខ្លាចគុណភាពទឹកស្រទាប់លើក្នុងតំបន់នេះនឹងទទួលរងការបំពុលដោយជាតិគីមី តែបច្ចុប្បន្នគុណភាពទឹកស្រទាប់លើក្នុងតំបន់នេះនៅពុំទាន់រងនូវការបំពុលដោយជាតិគីមីអ្វីឡើយ ហើយប្រជាជននៅក្នុងតំបន់នោះបានប្រើប្រាស់ទឹកពីប្រភពទាំងនោះក្នុងរដូវប្រាំង និងរដូវវស្សាទៀតផង។

**៧២.** ការប្រើប្រាស់ដីនៅតាមបណ្តោយផ្លូវចូលទៅកាន់តំបន់រ៉ែមានមួយប្រភេទគឺ: ដីស្រែ ដែលភាគច្រើនប្រើសំរាប់ធ្វើស្រូវវស្សាតែធ្វើតែមួយរដូវប៉ុណ្ណោះ។ បន្ទាប់ពីប្រមូលផលស្រូវហើយដីនឹងនៅទំនេរ រហូតដល់រដូវបង្កបង្កើនផលឆ្នាំក្រោយ។

**៧៣. ការយកសំណាកទឹក និងការវិភាគ:** ក្រុមការងារបានយកសំណាកទឹកចំនួន ០២សំណាក កាលពីថ្ងៃ ទី ១៦ ខែ កក្កដា ឆ្នាំ ២០១០ គឺ សំណាកទី-១: យកពីអូរភ្នៅ ដែលមានចំណុចនិយាមកា ៤៨៧៨២៩-១៤៧៩៤១៤ និងសំណាកទី-២ យកពីស្រះក្បែរទីស្នាក់ការរបស់ក្រុមហ៊ុន ៤៩៣៧៧២-១៤៧៩១៩៦ ដើម្បីធ្វើការវិភាគអំពីលក្ខណៈរូប និងលក្ខណៈគីមី។ សំណាកទាំងពីរនេះត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍របស់ក្រសួងដើម្បីធ្វើការវិភាគ (ឧបសម្ព័ន្ធ៥-២: **លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថាន**)។

**៧៤. សំណាកទី-១:** តាមរយៈការវិភាគលទ្ធផលវិភាគទឹក ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន រួចមកបង្ហាញថា (១) **លក្ខណៈរូប** - នៅក្នុងចំណោមថាវ៉ារូបបន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននៅក្នុងសំណាកទី-១ នេះ មានខ្ពស់ជាងកំរិតស្តង់ដារបស់ទឹក ដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់របស់ក្រសួងបរិស្ថាន និងអង្គការសុខភាពពិភពលោក ពោលគឺ ៣០/១០ ចំពោះ Total

Coliform និង ១១៨/១00 ចំពោះ Total Bacteria និង (**២**) **លក្ខណៈគីមី** - នៅក្នុងចំណោមថាវ៉ូបទាំង ២0 មាន ថាវ៉ូបចំនួន0៤ ក្នុងនោះមាន0៣ជា Trace Metals (Nickel –ND< 0.0004mg/l, Cobalt – 0.0004 mg/l and Mercury – 0.0008mg/l) ចំណែកតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែនវិញមានត្រឹមតែ pH = ៧.0៨ តែប៉ុណ្ណោះ ពោលគឺត្រូវនឹងកំរិតស្តង់ដារពី ៦.៥-៧.៥។ ការវិភាគពីកត្តាចំណីរបស់ទឹកជាធម្មតា គឺត្រូវផ្តោតជាសំខាន់ទៅលើអង្គធាតុសំខាន់ចំនួន0២ ដែលចាំបាច់សម្រាប់រុក្ខជាតិ និងវ៉ីរជាតិគឺ អាសូត និងហ្វូស្ហ ; នៅក្នុងទម្រង់ជានីត្រាត - NO3- និងអ៊ីយ៉ុងហ្វូស្ហាត - PO43- ។ ទោះបីជានៅក្នុងលទ្ធផលវិភាគទឹករបស់ក្រសួងមិនបានបង្ហាញពីវត្តមានរបស់អ៊ីយ៉ុងហ្វូស្ហាត - PO43- តែបរិមាណនីត្រាតដែលមាននៅក្នុងទឹកនេះមានតែ 0.១៥មីលីក្រាមប៉ុណ្ណោះ ពោលគឺទាបជាងកំរិតស្តង់ដារ១ហួតដល់ទៅ ១៥ដងឯណោះ។ ចំណែកឯថាវ៉ូបចំនួន១៥ ផ្សេងទៀត មិនមានអ្វីគួរអោយធ្វើការកត់សំគាល់ទេ (**ឧបសម្ព័ន្ធ៥-២ : តារាង១ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថាន**) ។

**៧៥. សំណាកទី-២:** តាមរយៈការវិភាគលទ្ធផលវិភាគទឹក ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន រួចមកបង្ហាញថា (**១**) **លក្ខណៈរូប** - នៅក្នុងចំណោមថាវ៉ូបបន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននៅក្នុងសំណាកទី-២ នេះ មានខ្ពស់ជាងកំរិតស្តង់ដាររបស់ទឹក ដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់របស់ក្រសួងបរិស្ថាន និងអង្គការសុខភាពពិភពលោក ពោលគឺ ៣៦/១0 ចំពោះ Total Coliform និង ១0៥/១00 ចំពោះ Total Bacteria និង (**២**) **លក្ខណៈគីមី** - នៅក្នុងចំណោមថាវ៉ូបទាំង ២0 មានថាវ៉ូបបន្ត ចំនួន0៤ ក្នុងនោះមាន0៣ជា Trace Metals (Nickel –ND< 0.0004mg/l, Cobalt – 0.001mg/l and Mercury –ND< 0.0005mg/l) ចំណែកតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែនវិញមានត្រឹមតែ pH = 7.40 តែប៉ុណ្ណោះ ពោលគឺ ត្រូវនឹងកំរិតស្តង់ដារពី ៦.៥-៧.៥ ។ ការវិភាគពីកត្តាចំណីរបស់ទឹកជាធម្មតា គឺត្រូវផ្តោតជាសំខាន់ទៅលើអង្គធាតុសំខាន់ ចំនួន0២ ដែលចាំបាច់សម្រាប់រុក្ខជាតិ និងវ៉ីរជាតិគឺ អាសូត និងហ្វូស្ហ ; នៅក្នុងទម្រង់ជានីត្រាត - NO3- និងអ៊ីយ៉ុង ហ្វូស្ហាត - PO43- ។ ទោះបីជានៅក្នុងលទ្ធផលវិភាគទឹករបស់ក្រសួងមិនបានបង្ហាញពីវត្តមានរបស់អ៊ីយ៉ុងហ្វូស្ហាត - PO43- តែបរិមាណនីត្រាតដែលមាននៅក្នុងទឹកនេះមានតែ ND<0.១ មីលីក្រាមប៉ុណ្ណោះ ពោលគឺទាបជាងកំរិតស្តង់ដារ១ហួតដល់ទៅ ៣0ដងឯណោះ។ ចំណែកឯថាវ៉ូបចំនួន១៥ ផ្សេងទៀត មិនមានអ្វីគួរអោយធ្វើការកត់សំគាល់ទេ (**ឧបសម្ព័ន្ធ៥-២: តារាង២ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថាន**) ។

## ខ- ធនធានអេកូឡូស៊ី

**៧៦.** សារព័ន្ធព្រៃឈើនៅលើទីតាំងស្នើសុំរបស់ក្រុមហ៊ុន DELCOM (KAMPUCHEA) PTE.LTD. បានកើតមានឡើងដោយសារប្រភេទសារព័ន្ធរុក្ខជាតិសំខាន់ៗ។ កំណើតដើមនៃប្រភេទព្រៃទាំងនេះអាស្រ័យ

ទៅនឹងអាកាសធាតុរបស់តំបន់លក្ខណៈភូមិសាស្ត្រសណ្ឋានដី និងសមាសភាពនៃប្រភេទឈើ ហើយប្រភេទព្រៃសំខាន់ៗទាំងនេះបានកើតឡើងដោយសារអនុប្រភេទជាច្រើនទៀត។ ឯកសារយោងដែលបានប្រើនៅក្នុងរយៈពេលនៃការសិក្សា និងអង្កេតដែលធ្វើឡើងក្នុងតំបន់នេះ តាមរូបភាពផ្កាយរណបឆ្នាំ ១៩៩២-១៩៩៣, ១៩៩៧, ២០០២ និង ២០០៦ របស់ UNDP GIS Dataset និងរដ្ឋបាលព្រៃឈើ (**ឧបសម្ព័ន្ធ៥-១ : ផែនទី ៦-៩ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**)។ នៅក្នុងរយៈពេលនៃការវាយតំលៃជាក់ស្តែងអំពីតំលៃអេកូឡូស៊ី និង តំលៃពាណិជ្ជកម្មរបស់ព្រៃបានបញ្ជាក់ថា ស្ថានភាពអេកូឡូស៊ីនៅក្នុងតំបន់នេះត្រូវបានទទួលរងការរំខានមធ្យម ចំណែកឯឈើដែលមានតំលៃពាណិជ្ជកម្មវិញ ត្រូវបានដកហូតស្ទើរតែទាំងស្រុង លើកលែងតែប្រភេទឈើដែលមិនជាទីពេញនិយមសំរាប់ទីផ្សារប៉ុណ្ណោះ ដែលមាននៅសេសសល់ក្នុងតំបន់នេះ ដូចជាស្រឡៅជាដើម។ ការសិក្សា អំពីការប្រែប្រួលស្ថានភាពសារពើរុក្ខជាតិក្នុងតំបន់ស្នើសុំនេះចាប់ពីឆ្នាំ ១៩៩២ -២០០៦ បង្ហាញថា:

- ចាប់ពីឆ្នាំ១៩៩២-១៩៩៣ ក្នុងតំបន់សម្បទានទាំងមូលមានសហគមន៍សារព័ន្ធរុក្ខជាតិ ចំនួនមួយប្រភេទប៉ុណ្ណោះ គឺដីមានគំរបព្រៃ ឬអាចយល់បានថាជាព្រៃបៃតងជានិច្ច។
- ចាប់ពីឆ្នាំ១៩៩៦-១៩៩៧ ក្នុងតំបន់សម្បទានទាំងមូលមានសហគមន៍សារព័ន្ធរុក្ខជាតិចំនួនមួយប្រភេទប៉ុណ្ណោះ គឺជាដីមានគំរបព្រៃ ឬជាព្រៃបៃតងជានិច្ច។
- ចាប់ពីឆ្នាំ២០០២ ក្នុងតំបន់សម្បទានទាំងមូលមានសហគមន៍សារព័ន្ធរុក្ខជាតិ ចំនួនពីរប្រភេទប៉ុណ្ណោះ គឺព្រៃស្រោង និងព្រៃល្បោះ។
- ចាប់ពីឆ្នាំ២០០៦ ក្នុងតំបន់សម្បទានទាំងមូលមានសហគមន៍សារព័ន្ធរុក្ខជាតិ ចំនួនពីរប្រភេទប៉ុណ្ណោះ គឺព្រៃស្រោង និងព្រៃល្បោះ។

**លំនាំនៃការប្រើប្រាស់ដី**

**៧៧.** ជាច្រើនជំនាន់មកហើយរាល់សកម្មភាពសេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជាមួយផ្នែកធំ គឺផ្អែកលើរបរកសិកម្ម ដែលបានប្រមូលផ្តុំនៅជុំវិញតំបន់ទំនាបទន្លេមេគង្គ។ ដំណាំកសិកម្មដែលមានគឺ: ស្រូវ កៅស៊ូ ពោត សណ្តែក កប្បាស អំពៅ ម្ទាស់ និងបន្ថែផ្សេងៗទៀត។ ប៉ុន្តែថ្មីៗនេះសង្កេតឃើញមានការរីកដុះដាលនូវចលនានៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច សម្បទានរ៉ែ សម្រាប់ការអភិវឌ្ឍន៍ជាច្រើន ដែលជាទិសដៅរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រជនបទ តាមរយៈការទាក់ទាញវិនិយោគិនអោយធ្វើការវិនិយោគក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ និងអភិរក្សធនធានធម្មជាតិ ដែលសម្បូរណ៍បែបនៅក្នុងប្រទេសកម្ពុជា ដោយរក្សាបាននូវចេរភាពនៃការអភិវឌ្ឍន៍។

**៧៨.** គួរអោយកត់សំគាល់ផងដែរថា ការផ្លាស់ប្តូរនូវលំនាំនៃការប្រើប្រាស់ដីនៅក្នុងប្រទេសយើង គឺកើតមានឡើងដោយសារ ហាយនភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ក្នុងរយៈពេលនៃបណ្តាឆ្នាំដែលសង្គ្រាម

ស៊ីវិលបានអូសបន្ទាយរ៉ាំរ៉ៃ ក្នុងនោះផ្ទៃដីមួយភាគធំត្រូវបានបោះបង់ចោល ហើយបន្ទាប់មកក៏ក្លាយទៅជាដីដែលគ្មានជីវជាតិ។ គ្រោះថ្នាក់ជាបន្តបន្ទាប់ដែលកើតមានឡើង ដោយមិនអាចទាយទុកបាននៃឆ្នាំមហន្តរាយធម្មជាតិ បានជំរុញអោយមានការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជនជនបទ។ ដោយសារតែកត្តាធម្មជាតិ និង កត្តាសត្វចង្រៃ បំផ្លាញដំណាំបានធ្វើអោយការធ្វើកសិកម្មតាមតំបន់ទំនាប មានការរងសំពាធយ៉ាងធ្ងន់ធ្ងរ។

**៧៩.** នៅក្នុងបរិបទនៃការរក្សាទីកទុកព្រៃឈើមានពហុមុខងារអេកូឡូស៊ីសំខាន់សំរាប់រុក្ខជាតិ ក្នុងការការពារ និងទប់ស្កាត់ការហូរច្រោះដី ដំណុះខ្សាច់នៅតាមបាតស្ទឹង និងប្រភពទីកនានា និងទីកជំនន់ក្នុងតំបន់ទំនាប។ ជាពិសេសប្រភេទព្រៃនៅតំបន់ទាំងបី រឹតតែមានសារៈសំខាន់ថែមទៀតក្នុងការជួយទប់ស្កាត់ការហូរច្រោះ។

**ស្ថានភាព និងការប្រែប្រួលរបស់គំរបព្រៃ**

**៨០.** តាមរយៈការវិភាគអំពីការប្រែប្រួលអំពីស្ថានភាពរបស់គំរបព្រៃក្នុងតំបន់ដែនសម្បទានទាំងមូល នៅក្នុងរយៈពេល១៤ឆ្នាំ ចុងក្រោយដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យ របស់ UNDP Dataset, ១៩៩២-៩៣, ១៩៩៦-៩៧ និង FA GIS Dataset ២០០២ និង ២០០៦ បានបង្ហាញ អោយដឹងថា ស្ថានភាពគំរបព្រៃនៅទូទាំងតំបន់សម្បទានរ៉ែនេះត្រូវបានបាត់បង់អស់ចំនួន ៥០ហិកតា ឬស្មើនឹង ៥០ភាគរយ បើប្រៀបធៀបជាមួយនឹងផ្ទៃដីដែលមានគំរបព្រៃសរុប (ឬជាព្រៃបៃតងជានិច្ច)។

**៨១.** យោងតាមរូបភាពផ្កាយរណប - UNDP Dataset, ១៩៩២-១៩៩៣ (**ឧបសម្ព័ន្ធ៥-១ : ផែនទី៦ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) បានបង្ហាញថា ស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់ស្នើសុំនេះគឺ:

| | | |
|---|---|---|
| - ដីមានគំរបព្រៃ | ១០០ ហិកតា | = ១០០ភាគរយ |

**៨២.** យោងតាមរូបភាពផ្កាយរណប - UNDP Dataset, ១៩៩៦-១៩៩៧ (**ឧបសម្ព័ន្ធ៥-១ : ផែនទី៧ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) បានបង្ហាញថា ស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់ស្នើសុំនេះគឺ

| | | |
|---|---|---|
| - ដីមានគំរបព្រៃ | ១០០ ហិកតា | = ១០០ភាគរយ |

**៨៣.** យោងតាមរូបភាពផ្កាយរណប - UNDP Dataset, ២០០២ (**ឧបសម្ព័ន្ធ៥-១ : ផែនទី៨ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) បានបង្ហាញថា ស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់ស្នើសុំនេះគឺ

| | | |
|---|---|---|
| - ព្រៃស្រោង | ១០ ហិកតា | = ១០ភាគរយ |
| - ព្រៃល្បោះ | ៩០ ហិកតា | = ៩០ភាគរយ |
| សរុប | ១០០ ហិកតា | = ១០០ភាគរយ |

**៨៤.** យោងតាមរូបភាពផ្កាយរណប - UNDP Dataset, ២០០៦ (**ឧបសម្ព័ន្ធ៥-១ : ផែនទី៥ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) បានបង្ហាញថា ស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់ស្នើសុំនេះគឺ

| | | |
|---|---|---|
| - ព្រៃស្រោង | ១០ ហិកតា | = ១០ភាគរយ |
| - ព្រៃល្បោះ | ៩0 ហិកតា | = ៩0ភាគរយ |
| សរុប | ១00 ហិកតា | = ១00ភាគរយ |

**៨៥.** យោងតាមរូបភាពផ្កាយរណប (UNDP, FA GIS Dataset, ១៩៩២-១៩៩៣, ១៩៩៦-១៩៩៧, ២00២ និង ២00៦ បានបង្ហាញថា ស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃនៅក្នុងតំបន់ស្នើសុំនេះ មានការប្រែប្រួលគួរអោយកត់សំគាល់ដូចខាងក្រោម ដោយក្នុងនោះសហគមន៍សារព័ន្ធរុក្ខជាតិបានកើនឡើងពីមួយប្រភេទទៅពីរប្រភេទ។

**តារាង៥-៤: ការប្រែប្រួលស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃនៅក្នុងតំបន់ស្នើសុំ**

| ប្រភេទព្រៃ | ១៩៩២-៩៣ | ១៩៩៦-៩៧ | ២00២ | ២00៦ |
|---|---|---|---|---|
| ដីមានគំរបព្រៃ | ១00 | ១00 | - | - |
| ព្រៃស្រោង | - | - | ១0 | ១0 |
| ព្រៃល្បោះ | - | - | ៩0 | ៩0 |

**៨៦.** តាមការពិនិត្យទៅលើផែនទីគំរបព្រៃឆ្នាំ២00៦ បង្ហាញថា ក្នុងដែនសម្បទានទាំងមូលមានព្រៃស្រោងចំនួន១0ហិកតា ស្មើនឹង ១0ភាគរយ និង ព្រៃល្បោះចំនួន ៩0ហិកតា ស្មើនឹង ៩0ភាគរយ ។ ឈើភាគច្រើនស្ថិតក្នុងអំបូរ *Dipterocarpaceae* ជាឈើដែលមានតំលៃពាណិជ្ជកម្ម។ ដោយឡែកចំពោះប្រភេទឈើប្រណិតមានមួយចំនួនដូចជា: ប្រាំតំឡឹង *(Combretaceae)* បេង *(Caesalpiniaceae)* ត្រយឹង *(Ebenaceae)* ធ្នង់ *(Papilionaceae)* នាងនួន *(Papilionaceae)* និងក្រញូងនៅមានវត្តមានតិចតួចបំផុតសំរាប់តំបន់នេះ។ ចំណែកឯ តាត្រាវ *(Loganiaceae)* ត្រើល *(Anacardiaceae)* អង្គត់ខ្មៅ *(Ebenaceae)* ឈើខ្មៅ *(Ebenaceae)* យើងពុំសង្កេតឃើញមានវត្តមាន នៅក្នុងតំបន់នោះទេ។ ប្រភេទឈើដែលប្រទះឃើញមាន នៅក្នុងតំបន់ដីសម្បទានរ៉ែនេះមានដូចជា:

| ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអំបូរ |
|---|---|---|
| កកោះ | *Sindora cochinchinensis* | *Caesalpiniaceae* |
| ឈ្លីក | *Terminalia tomentosa* | *Combretaceae* |
| ពពួល | *Vitex sp* | *Verbenaceae* |
| សុក្រម | *Xylia dolabriformis* | *Mimosaceae* |

| | | |
|---|---|---|
| ក្ការ | *Adina cordifolia* | *Dipterocarpaceae* |
| ត្នង | *Dipterocarpus tuberculatus* | *Dipterocarpaceae* |
| ស្រូល | *Poducarpus cupressina* | *Podocarpaceae* |
| ច្រម៉ាស់ | *Vatica astrotricha* | *Dipterocarpaceae* |
| កណ្តាល | *Careya sphaerica* | *Myrtaceae* |
| ព្រីង | *Eugenia sp.* | *Myrtaceae* |
| ព្ញេស | *Garcinia ferrea* | *Guttiferes* |
| ត្រមូង | *Garcinia schomburghiana* | *Guttiferes* |
| ក្រាយ | *Kayea engeniafolia* | *Guttiferes* |
| ស្ពាក្របី | *Knema corticosa* | *Myristicaceae* |
| ធ្ពក | *Parinarium annamensis* | *Rosaceae* |
| ស្វាយព្រៃ | *Swintonia pierri* | *Anacardiaceae* |
| ផ្ទីក | *Shorea obtusa* | *Dipterocarpaceae* |
| ឃ្មាស (ក្ស្យាស) | *Memecylon edule* | *Melastomaceae* |
| ល្ស្យាង | *Cratoxylum formosum subsp* | *Guttiferes* |
| តាឡាត់ | *Canarium album* | *Burseraceae* |
| ភ្ជួបាត | *Dillenia hookeri* | *Dilleniaceae* |
| ញ្ញូព្រៃ (ញ្ញូធំ) | *Morinda tomenta* | *Rubiaceae* |
| ស្ពៅ | *Azadirachta indica* | *Meliaceae* |
| កន្ទួតព្រៃ | *Phyllanthus emblica* | *Euphorbiaceae* |
| ពពាលខ្ចៃ | *Alstonia scholaris* | *Apocynaceae* |

Source of families and scientific names: National priority tree species workshop, Cambodia Tree Seed Project/DANIDA, 2000.

**៨៧.** ដោយផ្អែកលើការអង្កេត និងវាយតំលៃទៅលើប្រភេទព្រៃបង្ហាញថា (១) ប្រភេទព្រៃល្បោះ ស្រទាប់ទី១ មានកំពស់ពី៩-១៤ម និងស្រទាប់ទី២ មានកំពស់ពី៥-៨ម។ រីឯរុក្ខជាតិថ្នាក់ក្រោម ជាស្មៅព្រិចស្ស្ងួ និងកូនឈើតូចៗ ហើយមានសភាពស្ងួតខ្លាំងនៅរដូវប្រាំង ដែលអាចងាយនឹងបង្ករអោយមានភ្លើងឆេះ និង (២) ព្រៃពាក់កណ្តាលស្រោង ស្រទាប់ទី១ មានកំពស់ពី១០-១៨ម និងស្រទាប់ទី២ មានកំពស់ពី ៨-១០ម។ រីឯរចនាសម្ព័ន្ធថ្នាក់ក្រោមមានប្រភេទកូនឈើតូចៗ និងស្មៅតិចតួច។

**៨៨.** នៅក្នុងព្រៃល្បោះ ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង៥០ស.មឡើង មានពី១-៤ដើមក្នុង១ហិកតា គិតជាមធ្យមមាន១.៥ដើមក្នុង១ហិកតា។ ដូច្នេះនៅលើផ្ទៃដីព្រៃល្បោះចំនួន៩០ហិកតា ឈើដែលមានអង្កត់ផ្ចិតធំជាង៥០ស.មឡើង មានចំនួនសរុប១៣០ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី៣០-៤៩ស.ម មានពី ១៧-២១ដើមក្នុង១ហិកតា គិតជាមធ្យមមាន១៩ដើមក្នុង១ហិកតា។ ដូច្នេះលើផ្ទៃព្រៃល្បោះចំនួន៩០ ហិកតា ឈើដែលមានអង្កត់ផ្ចិតពី៣០-៤៩ស.ម មានចំនួនសរុប១៧១០ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី១០-២៩ មានពី២៨-៣៦ដើមក្នុង១ហិកតា គិតជាមធ្យមមាន៣៣ដើមក្នុង១ហិកតា។ ដូច្នេះលើផ្ទៃដីព្រៃល្បោះចំនួន ៩០ហិកតា ឈើដែលមានអង្កត់ផ្ចិតពី១០-២៩ មានចំនួនសរុប ២៩៧០ដើម។ ចំណែកឯដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី៥-៩ស.ម មានពី៦៤-៧៧ដើមក្នុង១ហិកតា គិតជាមធ្យមមាន៧០ដើមក្នុង ១ហិកតា។ ដូច្នេះ នៅលើផ្ទៃដីព្រៃល្បោះចំនួន៩០ហិកតា ឈើដែលមានអង្កត់ផ្ចិតពី៥-៩ស.ម មានចំនួនសរុប ៦៣០០ដើម។ គំរបព្រៃក្នុង តំបន់នេះមានជាមធ្យម១៨ភាគរយនៃផ្ទៃដីល្បោះសរុប។

**៨៩.** ជាការពិតណាស់អន្តរកម្មរវាងជីវៈចំរុះនៅក្នុងតំបន់មួយ ស្តែងចេញនូវភាពខុសប្លែកគ្នាពីសារពាង្គកាយមួយទៅសារពាង្គកាយមួយទៀត។ វត្តមាននៃប្រភេទសត្វដែលរស់នៅក្នុងព្រៃក៏មានភាពខុសប្លែកគ្នាពីតំបន់មួយទៅតំបន់មួយដែរ ដោយអាស្រ័យលើលក្ខខ័ណ្ឌចំណីអាហារ ទីជំរក និងមជ្ឈដ្ឋាននៃការរស់នៅ។ តាមដំណើរការអង្កេត (សំរ៉ែក ដានជើង និងលាមក) និងការសំភាសន៍មួយប្រជាជនដែលរស់នៅក្បែរទីនោះបានអោយដឹងថា នៅក្នុងតំបន់សម្បទាននេះគេប្រទះឃើញមានវត្តមានសត្វឈ្លូស ពស់ ជ្រូកព្រៃ ទន្សាយ សំពោច ក្តាន់ញ៉ែង អណ្តើកព្រិច។ល។ តាមរយៈការសាកសួរប្រជាជនដែលរស់នៅ តំបន់ដដែលនោះក៏បានអោយដឹងផងដែរ ថាប្រភេទសត្វចតុប្បាទធំ១ ( ប្រើស ខ្ទីង ជ័រ ខ្លាឃ្មុំ ខ្លារខិន ខ្លាដំបង) ពុំមានវត្តមាន ឬផ្ទងកាត់ក្នុងតំបន់នេះ ដូចពីមុនទៀតទេ។

**៩០.** ចំពោះសត្វស្លាបដែលក្រុមសិក្សាសង្កេតឃើញ ដោយបង្ហាញពីវត្តមានសត្វតាមរយៈ ដានជើង សំរ៉ែក និងលាមក សង្កេតឃើញមានដូចជា: មាន់ព្រៃ គូក ចាបទ្រូងលឿង ទទារ លលក ចាប ត្រសេះ ប្រវ៉ាង ក្រូចអឹត សារិកាកែវ កូនលោក ទាវ។ល។ តាមរយៈការសាកសួរប្រជាជនដែលរស់នៅក្បែរតំបន់សម្បទានបានអោយដឹងថា មិនឃើញមានសត្វស្លាបធំ១ទេ។

**៩១.** ចំពោះមច្ឆាជាតិនៅក្នុងតំបន់សម្បទានរ៉ែមិនសំបូរប្រភពទឹកស្រទាប់លើទេ ពោលគឺមានតែអូរ ដែលស្ថិតនៅក្បែរបណ្តាយព្រំខាងលិចរបស់ដីសម្បទាន និងដៃអូរមួយនៃអូរភ្នៅ ដែលហូរកាត់តំបន់ដីសម្បទានពីទិសខាងត្បូងទៅខាងលិចប៉ុណ្ណោះ។ តាមការសាកសួរពីប្រជាពលរដ្ឋនៅក្នុងតំបន់បញ្ជាក់ថា ពួកគាត់ធ្លាប់នេសាទបាននូវប្រភេទត្រីមួយចំនួន (ទាំងប្រភេទត្រីស និងត្រីខ្មៅ) នៅក្នុងតំបន់នោះ។ ប្រភេទត្រីសំខាន់ៗ

ដែលពួកគាត់ធ្លាប់នេសាទមានដូចជា: **(១) ត្រីសៈ** ត្រីរ្យៀលអង្ការ (Henicorthynechus lobatus), ត្រីចង្ហារនោង (Luciosoma setigerum), **និង (២) ត្រីខ្មៅ:** ត្រីផ្ទក់ (Channa Striata),ត្រីឆ្ទាំង (Hemibagrus spilopterus) ត្រីអណ្តែងងាំង (Clarias nieuhofii), ត្រីអណ្តែងរ៉ែង (Clarias batrachus), ត្រីស្លាត (Notopterus notopterus), ត្រីខ្ជ្ជ (Macrognathus semiocellatus), ត្រីឆ្ពញ (Macrognathus siamensis), ត្រីក្រាញ់ (Anabas testudineus) ។

## គ- ការអភិវឌ្ឍន៍សេដ្ឋកិច្ច

**៩២.** ក្រៅពីក្នុងទីរួមខេត្ត ដីដែលនៅតាមសងខាងបណ្តោយផ្លូវ (ព្រះវិហារ-រវ៉ែង) ភាគច្រើនគឺជនបទ។ ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចក្នុងតំបន់នេះមានលក្ខណៈ (តាមទីប្រជុំស្រុក) មានលក្ខណៈប្រហាក់ប្រហែលគ្នា គឺការប្រកបរបរកសិកម្ម (ការធ្វើស្រែ និងដំណាំរួមផ្សំ) និងជីករ៉ែមាស។

**៩៣.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍ មានលក្ខណៈផ្សេងៗគ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយៗ។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អាត្រានៃភាពក្រីក្រនៅក្នុងខេត្តព្រះវិហារមាន ២៩.១ភាគរយ (៣២.៩ពាន់) លើចំនួនប្រជាជនសរុប ១៤១.៧៤៩នាក់ ក្នុងនោះមាន ១៣៣.១៩៨នាក់ ឬស្មើនឹង ៩៤ភាគរយ រស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀងអង្គការសហប្រជាជាតិ ឆ្នាំ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៤) ។ ចំនួនអ្នកមិនចេះអក្សរសរុបមាន ២៧.៨០៣នាក់ (ប្រុស ១១.៩៨៦នាក់ ស្ត្រី ១៥.៨១៧នាក់) នៅក្នុងខេត្តព្រះវិហារទាំងមូល។

**៩៤.** គួរបញ្ជាក់ថា លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (ការផ្គត់ផ្គង់អគ្គីសនី ទឹកស្អាត គមនាគមន៍ សេវាអប់រំ និងសុខាភិបាល) នៅក្នុងសហគមន៍ទាំងនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ បើប្រៀបធៀបជាមួយនឹងគ្រួសារសហគមន៍នៅក្នុងតំបន់ដទៃទៀតរបស់ប្រទេសកម្ពុជា (តំបន់ទីប្រជុំជនខេត្ត) ។ ការសិក្សាបានបង្ហាញអោយឃើញថា អ្នកភូមិក្នុងឃុំរម្យទម ពុំបានទទួលការផ្គត់ផ្គង់អគ្គីសនីជាមូលដ្ឋានទេ។ ចំពោះបណ្តាញអគ្គិសនីនៅក្នុងតំបន់នោះគឺពុំទាន់មាននៅឡើយ គឺមានត្រឹមតែការប្រើប្រាស់អាគុយ ប៉ុន្តែភាគច្រើនប្រើចង្កៀងប្រេងកាត និងចន្ទុះសំរាប់បំភ្លឺនៅពេលយប់។ រីឯការចំអិនអាហារវិញ គឺពួកគាត់ប្រើអុសដែលរកបានពីព្រៃនៅក្បែរៗភូមិ ឬទៅរកពីព្រៃដែលមានចំងាយ ០.៥-១.៥គីឡូម៉ែត្រពីភូមិ។

**៩៥.** ការប្រើប្រាស់ទឹកស្អាតក៏នៅមានកំរិត ជាក់ស្តែងនៅក្នុងភូមិនិមួយៗនៃឃុំរម្យទម ក្នុងតំបន់គំរោង ពុំមានអណ្តូងស្នប់ប្រើប្រាស់គ្រប់គ្រាន់ទេ ភាគច្រើនគឺពួកគាត់ប្រើប្រាស់ទឹកអណ្តូងលូ អណ្តូងជីកដៃ ទឹកអូរ

ស្ទឹងសំរាប់បរិភោគ និងប្រើប្រាស់ផ្សេងៗ ដែលនៅរដូវវស្សា ទឹកសំរាប់ប្រើប្រាស់ពុំមានបញ្ហាចោទទេ ដោយប្រជាពលរដ្ឋខ្លះប្រើទឹកអណ្តូងស្នប់ និងខ្លះទៀតត្រង់ទឹកភ្លៀងមកប្រើ ប៉ុន្តែនៅរដូវប្រាំងវិញបងប្អូនប្រជាពលរដ្ឋជួបប្រទះការខ្វះខាតទឹក ដោយសារអណ្តូងជីកដៃ អូរមួយចំនួនធំត្រូវបានរីងស្ងួត ហើយអណ្តូងលូភាគច្រើន និងអណ្តូងស្នប់មួយចំនួនមានបរិមាណទឹកតិច ដូច្នេះត្រូវបង្ខំចិត្តប្រើប្រាស់ទឹកមិនស្អាតដែលបានមកពីប្រភពមួយចំនួនដូចជា អូរ និងស្ទឹងជាដើម ។

**៩៦.** ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើន គឺប្រើប្រាស់ផ្លូវជាតិលេខ៦២ (ទីរួមខេត្តកំពង់ធំ-ខេត្តព្រះវិហារ) ដែលជាផ្លូវយ៉ាងសំខាន់នៅក្នុងតំបន់នេះ ។ រីឯផ្លូវដែលតភ្ជាប់ផ្លូវជាតិទៅនឹងតំបន់សម្បទានរ៉ែនោះ ជាផ្លូវលំ ។ ចំណែកឯផ្លូវ ដែលតភ្ជាប់ពីផ្លូវទាំងនេះទៅសហគមន៍ពួកគាត់ភាគច្រើនជាផ្លូវលំ ក្នុងនោះមួយចំនួនជាផ្លូវក្រាលគ្រួសក្រហម ដែលកសាងដោយគំរោងអភិវឌ្ឍន៍ឃុំ ហើយមួយចំនួនទៀតជាផ្លូវរទេះ ឬផ្លូវលំដើរដោយជើង ។ ផ្លូវទាំងនេះនៅក្នុងរដូវវស្សាមានសភាពទ្រុឌទ្រោមពិបាកធ្វើដំណើរ ។

**ស្ថានភាពផ្ទះ និងទ្រព្យសម្បត្តិគ្រួសារ**

**៩៧.** តាមការអង្កេតផ្ទាល់ និងការប្រៀបធៀបជាមួយទិន្នន័យឃុំឆ្នាំ ២០០៩ យើងឃើញប្រជាពលរដ្ឋនៅក្នុងតំបន់នេះស្ទើរតែ ៦៥ភាគរយ មានផ្ទះឈើសង់ផុតពីដី ជញ្ជាំងក្តារ និងមានដំបូលប្រក់សង្កសី ទំហំ ៣ x ៩ ម៉ែត្រ ១០ភាគរយ ទៀតជាប្រភេទផ្ទះតំបូលប្រក់ក្បឿង និងក្រៅពីនោះជាប្រភេទផ្ទះស្លឹក ។

**ការគ្រប់គ្រង និងកម្មសិទ្ធិដីធ្លី**

**៩៨.** បើតាមសំដីរបស់លោកមេឃុំ និងប្រជាពលរដ្ឋមួយចំនួននៅក្នុងឃុំរមៀទមថា ពីដើមឡើយភូមិសុទ្ធតែ ជនជាតិកួយដែលមានកំណើតតាំងពីដូនតាមកម្លេះ ។ ដោយសារលំហូរចូលនៃអ្នកស្រុកដែលរស់នៅក្នុងតំបន់ផ្សេងដើម្បីមកកាប់ឈើ និងជីកយកមាសបានជំរុញអោយអ្នកភូមិមួយចំនួនបង្ខំចិត្តចាកចោលភូមិរត់ទៅនៅក្នុងព្រៃ ហើយមួយចំនួនទៀតបានប្រែក្លាយជីវភាព និងរបៀបរស់នៅរបស់ខ្លួនដូចទៅនឹងប្រជាជនខ្មែរដែរ ។ បច្ចុប្បន្ននេះអ្នកភូមិនៅក្នុងតំបន់នេះមានដីលំនៅដ្ឋានជាមធ្យម ១០០ម៉ែត្រក្រឡា (២០ម×៥០ម) ក្នុងមួយគ្រួសារ ។ តែភាគច្រើនក្នុងចំណោមពួកគាត់ពុំមានលិខិតបញ្ជាក់កម្មសិទ្ធិច្បាស់លាស់នៅឡើយទេ គឺមានត្រឹមតែលិខិតកាន់កាប់បណ្តោះអាសន្ន ដែលចេញដោយអាជ្ញាធរភូមិឃុំតែប៉ុណ្ណោះ ។ ដោយឡែក ចំពោះដីស្រែវិញជាមធ្យមគឺកន្លះហិកតាក្នុងមួយគ្រួសារ និងដីចំការវិញជាមធ្យមមាន ១ហិកតា ក្នុងមួយគ្រួសារ ។

**ប្រភពទឹកសំរាប់ប្រើប្រាស់:**

**៩៩.** ទឹកអណ្តូងស្នប់ គឺជាប្រភពទឹកដ៏សំខាន់សំរាប់ប្រជាជននៅក្នុងតំបន់នេះបរិភោគ និងប្រើប្រាស់សំរាប់ សត្វចិញ្ចឹមតាមលក្ខណៈគ្រួសារ។ អ្នកភូមិភាគច្រើនប្រើប្រាស់អណ្តូងស្នប់ (ឧបត្ថម្ភដោយអង្គការADRA) ព្រោះមានអនាម័យគ្រប់គ្រាន់ ដោយឡែកមានប្រជាជនខ្លះគាត់ប្រើប្រាស់អណ្តូងជីកដៃដែលនៅក្បែរផ្ទះរបស់គាត់ក្រុមការងារអង្កេតឃើញថា ការប្រើប្រាស់ពុំមានអនាម័យគ្រប់គ្រាន់នៅឡើយទេ ដោយសារពួកគាត់ពុំមានលទ្ធភាពធ្វើជាអណ្តូងលូ ដូច្នេះនៅរដូវវស្សាងាយស្រួលអោយទឹកក្រខ្វក់ដែលនាំដោយទឹកភ្លៀងហូរចាក់ទៅក្នុងអណ្តូង។ បើទោះជាយ៉ាងនេះក្តី ទឹកអូរនៅតែជើរតួនាទីសំខាន់សំរាប់ ផ្គត់ផ្គង់ដល់សកម្មភាពដាំដុះផ្សេងៗ និងរបរជីករ៉ែមាសរបស់អ្នកភូមិនៅតំបន់នេះដដែល។

**កំលាំងអូសទាញ និងការចិញ្ចឹមសត្ត**

**១០០.** គោ-ក្របីត្រូវបានគេចាត់ទុកថាជាកំលាំងអូសទាញដែលសំខាន់ជាងគេ សំរាប់បំរើបំរាស់នៅក្នុងការធ្វើស្រែ-ចំការ។ បើគិតជាមធ្យមក្នុងមួយគ្រួសារយ៉ាងហោចណាស់ក៏មានក្របី ឬគោមួយនឹមសំរាប់ជាកំលាំងអូសទាញដែរ។ លើសពីនេះទៅទៀត ក៏មានអ្នកភូមិមួយចំនួនកំពុងប្រើប្រាស់គោយន្តសំរាប់ជាកំលាំងអូសទាញជំនួសកំលាំងគោក្របីដែរជាពិសេសនៅភូមិទន្ទឹម។ ចំពោះយុទ្ធសាស្ត្រនៅក្នុងការចិញ្ចឹមសត្តពាហនៈរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះពុំទាន់បានល្អនៅឡើយទេ។

**ចំណេះដឹង និងការអប់រំ**

**១០១.** ដោយសារភាពមមាញឹកនៅក្នុងការងារស្រែចំការ យើងមើលឃើញថាមេគ្រួសារភាគច្រើនទទួលបានការអប់រំជាមូលដ្ឋានតិចតួចបើប្រៀបធៀបទៅនឹងប្រជាជននៅតំបន់ផ្សេង។ ការចុះឈ្មោះចូលរៀនរបស់កុមារដែលដល់អាយុចូលរៀនមានកំណើនឡើងគួរអោយកត់សំគាល់ក្នុងរយៈកាល ៣ ទៅ៤ឆ្នាំចុងក្រោយនេះ។ ដោយសារប្រជាពលរដ្ឋកាន់តែយល់ដឹងអំពីសារៈសំខាន់ក្នុងការសិក្សារបស់កុមារ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដែលបានកំពុងយកចិត្តទុកដាក់ខ្លាំងនៅក្នុងយុទ្ធសាស្ត្រដែលជំរុញ អោយកុមារបានចូលរៀន ១០០ភាគរយក្នុងកំរិតបឋមសិក្សា។ បើទោះជាយ៉ាងនេះក្តីយើងសង្កេតឃើញថា សាលារៀនថ្នាក់បឋមនៅក្នុងតំបន់នេះមិនទាន់បំពេញតំរូវការនៃកំណើនរបស់កុមារនៅឡើយទេ។ ចំពោះថ្នាក់លើសពីបឋមសិក្សាវិញ អ្នកភូមិត្រូវបញ្ជូន កូនអោយទៅរៀននៅឯចំណុចភ្នំដែកស្ថិតក្នុងឃុំរមៀណី ឬទៅស្រុករវៀង ។ អ្នកដែលមានឱកាសអោយកូនទៅរៀននៅទីរួមស្រុកបាន មានមិនច្រើនន៏ោះ ទេដោយសារពួកគេភាគច្រើនជាប់រវល់នៅក្នុងសកម្មភាពបង្កបង្កើនផលក្នុងគ្រួសារ និងណាមួយចំងាយពីផ្ទះ ទៅសាលាមានចំងាយឆ្ងាយ (១៦-២០គីឡូម៉ែត្រ)។

## សុខភាព និងអនាម័យ

**១០២.** នៅក្នុងរយៈកាលបីឆ្នាំចុងក្រោយនេះអ្នកភូមិហាក់ដូចបានយល់កាន់តែច្បាស់អំពីសារៈសំខាន់នៅក្នុងការស្វែងរកសេវាសុខភាពដ៏ត្រឹមត្រូវនៅពេលដែលគាត់មានជំងឺដង្កាត់ផ្សេងៗ។ ពីមុនដោយសារស្រុកនេះជាស្រុកព្រៃ ហើយសេវាសុខភាពសាធារណៈពុំទាន់មាននៅឡើយនោះ អ្នកភូមិនិយមជឿជាក់លើថ្នាំខ្មែរ និងទទួលយកការព្យាបាលបែបបូរាណនៅពេលដែលពួកគាត់មានជំងឺដង្កាត់ផ្សេងៗ។ ចំពោះសេវាសុខាភិបាលវិញ ក្នុងឃុំមិនទាន់មានលក្ខណៈប្រសើរនៅឡើយទេ ដោយក្នុងឃុំទាំងមូលមានតែប៉ុស្តិ៍សុខភាពតែមួយកន្លែងស្ថិតនៅក្នុងភូមិស្វាយដំណាក់ចាស់។ ទោះបីជាយ៉ាងណាក៏ដោយ បើតាមការសាកសួរគឺមានឆ្មបបណ្តុះបណ្តាលនៅតាមភូមិនីមួយៗ។ ពេលមានមនុស្សឈឺត្រូវបញ្ជូនអ្នកជំងឺទៅព្យាបាលនៅមណ្ឌលសុខភាពឃុំរម្យណី ឬស្រុករវៀង ឬអាចដាក់ឡានយកទៅពេទ្យបង្អែកខេត្តតែម្តង ដែលមានចម្ងាយផ្លូវពីឃុំទៅស្រុកគឺ ២០-២៣គីឡូម៉ែត្រ ឬពីឃុំទៅខេត្ត ៥០-៦០គីឡូម៉ែត្រ។

## មធ្យោបាយធ្វើដំណើរ និងការដឹកជញ្ជូន

**១០៣.** ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើន គឺប្រើប្រាស់ផ្លូវជាតិលេខ៦២ (ទីរួមខេត្តកំពង់ធំ-ខេត្តព្រះវិហារ) ដែលជាផ្លូវយ៉ាងសំខាន់នៅក្នុងតំបន់នេះ។ ទោះបីផ្លូវគមនាគមន៍ក្នុងតំបន់នេះ (ផ្លូវលំគ្រួសក្រហមទៅកាន់ភូមិផ្សេងៗ) មានការខូចខាត និងរអិល ដែលបណ្តាលមកពីទឹកភ្លៀងរដូវវស្សាលិច និងហូរកាត់ដោយកន្លែងៗ។ ដោយហេតុថា ផ្លូវក្នុងតំបន់នេះមានការលំបាកខ្លាំងក្នុងការធ្វើដំណើរប្រជាជនភាគតិចប្រើប្រាស់កង់ និងម៉ូតូជាមធ្យោបាយធ្វើដំណើរ និងធ្វើដំណើរដោយថ្មើរជើងភាគច្រើនពីភូមិមួយទៅភូមិមួយ។

## លទ្ធភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិ

**១០៤.** នៅក្នុងតំបន់នេះក្រៅពីធនធានរ៉ែមាស ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះហើយនោះ គេពុំឃើញមានធនធានធម្មជាតិ ដែលមានតំលៃដូចជាព្រៃឈើធំៗ និងបឹងទន្លេនោះទេ។ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនបានកំពុងរុករកប្រើប្រាស់ធនធានធម្មជាតិដែលមានតិចតួចនៅក្នុងតំបន់របស់ខ្លួន ដូចជាពួកគាត់អាចជីករកទំពាំងសំរាប់បរិភោគ និងមួយចំនួនតូចអាចលក់ដើម្បីជាចំនួលបន្ទាប់បន្សំ។ ក្រៅពីនេះប្រជាពលរដ្ឋអាចរកនេសាទត្រីតាមអូរភ្នៅ និងលើផ្ទៃដីលិចទឹកនារដូវវស្សា សំរាប់ជាម្ហូបអាហារបន្ថែមនៅក្នុងគ្រួសារ និងសំរាប់ដោះដូរជាអង្ករជាមួយអ្នកជិតខាងតែប៉ុណ្ណោះ។ ទោះជាធនធានរ៉ែមាសត្រូវបានគេដឹងថាមានសំបូរបែបនៅលើទឹកដីនៃតំបន់នេះក៏ដោយ ក៏បច្ចុប្បន្ននេះគេពុំសូវឃើញមានប្រជាពលរដ្ឋប្រកបរបរជីករករ៉ែ ដូចពីសម័យទសវត្សទី៨០-៩០ ទៀតឡើយ។

**ទិន្នផលកសិកម្ម**

**១០៥.** ប្រជាជនក្នុងឃុំទាំងមូលប្រភពចំណូលសំខាន់របស់ពួកគាត់គឺអាស្រ័យលើមុខរបរធ្វើស្រែចំការ (ទិន្នផលស្រូវទទួលបាន ១-២.៥តោនក្នុងមួយហិកតា) ចំពោះឃុំរម្យទមស្រូវ០១គីឡូក្រាម អាចលក់បានតំលៃពី ៧០០-១០០០រៀល និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារមានដូចជា គោ ក្របី ជ្រូក មាន់ ទាជាដើម។ ការចិញ្ចឹមគោ-ក្របីរបស់ពួកគាត់ មិនត្រឹមតែទុកសំរាប់ប្រើប្រាស់ជាមធ្យោបាយអូសទាញក្នុងវិស័យកសិកម្ម ប៉ុណ្ណោះទេ ព្រមទាំងអាចលក់ដូរសំរាប់ដោះស្រាយ វិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារថែមទៀតផង។ ដោយឡែកជ្រូករស់០១គីឡូក្រាម អាចលក់បានតំលៃ ៥.០០០រៀល ឬតំលៃ ៦.០០០រៀលក្នុងមួយគីឡូក្រាម ឯមាន់ និងទា អាចលក់បានតំលៃ ១២,០០០-១៥,០០០រៀលក្នុងមួយគីឡូក្រាម។ ចំពោះគ្រួសារមួយចំនួនដែលអាស្រ័យតែលើមុខរបរធ្វើស្រែ ពុំមានស្បៀងអាហារហូបគ្រប់គ្រាន់ទេ មានឆ្នាំខ្លះគ្រួសារទាំងនោះខ្វះខាតស្បៀងរហូតដល់ទៅ ៣-៤ខែឯណោះ។

## ឃ- ធនធានសង្គម និងវប្បធម៌

**១០៦.** ក្រុមការងារជាដំបូងបានធ្វើការសិក្សានៅឃុំរម្យទមមានភូមិចំនួន ០៦ មានប្រជាជនសរុបចំនួន ៥៣៧ គ្រួសារ ស្មើនឹង ៤៣៤៧នាក់ ក្នុងនោះប្រជាជនចំនួន ១៨៧១ នាក់ ជានារីភេទ តែភូមិទាំងនោះពុំមានជាប់ពាក់ព័ន្ធនឹងគំរោងដីសម្បទានរុករករ៉ែនេះទេ។

**តារាងស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០១០ ឃុំរម្យទម ស្រុកវ៉ារ៉ៃ**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋសរុប(នាក់) | ចំនួនស្ត្រីសរុប(នាក់) |
|---|---|---|---|---|
| ១ | ត្រពាំងទន្ទឹម | ២១៣ | ១១៧៣ | ៥៩៣ |
| ២ | ទួលរវ៉ៃង | ១៣១ | ៦១៧ | ៣១៩ |
| ៣ | អូរទ្រលោក | ២១២ | ៧៩៩ | ១៤០ |
| ៤ | បង្គ្រីនផល | ១២៨ | ៦០២ | ២៨៧ |
| ៥ | ស្វាយដំណាក់ថ្មី | ៩៧ | ៤២១ | ២០៣ |

| | | | | |
|---|---|---|---|---|
| ៦ | ស្វាយដំណាក់ចាស់ | ១៥៦ | ៧៣៥ | ៣២៩ |
| **សរុបរួម** | | **៩៣៧** | **៤៣៤៧** | **១៨៣១** |

* **<u>បញ្ជាក់</u>:** តាមការចុះសិក្សាបង្ហាញថា ទីតាំងដីសម្បទានដែលក្រុមហ៊ុន **DELCOM (KAMPUCHEA) PTE. LTD.** ស្នើសុំធ្វើអាជីវកម្មរុករករ៉ែមាស ពុំមានជាប់ពាក់ព័ន្ធនឹងភូមិទាំង០៦ខាងលើទេ ។

**១០៧.** លំនាំនៃការតាំងទីលំនៅរបស់ប្រជាជនមានលក្ខណៈជាជនបទ: (១) ពួកគាត់រស់នៅអមតាមសងខាងផ្លូវលំ និងអមតាមសងខាងផ្លូវជាតិលេខ៦២ក្រាលគ្រួសក្រហម (២) ការតាំងលំនៅដ្ឋានជាលក្ខណៈប្រមូលផ្តុំនៅតាមភូមិក្នុងព្រៃ (ភាគច្រើនជាជនជាតិកួយ) ដោយត្រូវធ្វើដំណើរដោយម៉ូតូ ឬកង់តាមផ្លូវទេះតូចចង្អៀត រអិល ជាប់ផុងដោយអន្ទើ១ពិបាកធ្វើដំណើរ និងត្រូវឆ្លងកាត់ព្រៃល្បោះដោយកន្ទែង ។ ក្នុងឃុំនៃតំបន់គំរោងនេះមានវត្តមានជនជាតិកួយប្រមាណជា៦៥ភាគរយ ក្រៅពីនេះសុទ្ធតែជនជាតិខ្មែរ ។

**១០៨.** **តាមការសិក្សារបស់ក្រុមការងារលើប្រភពព័ត៌មានដែលទទួលបានពីមូលដ្ឋានបង្ហាញថា នៅក្នុងទីតាំងតំបន់គំរោងនេះ ពុំមានសំណាក ឬសំណង់ប្រាសាទប្រវត្តិសាស្ត្រទេ ។**

Draft